នស/រកម/០៥០៨/០១៥

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជាតិរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានអនុម័តកាលពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្តីពី

# ការគ្រប់គ្រងពូជដំណាំ

## និង

# សិទ្ធិអ្នកបង្កាត់ពូជដំណាំ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះ មានគោលដៅ គ្រប់គ្រង និងត្រួតពិនិត្យលើការបង្កាត់ ការបញ្ចេញឱ្យប្រើ ការផលិត ការកែច្នៃ ការចុះបញ្ជី ការចែកចាយ ការនាំចូល នាំចេញពូជដំណាំ និង ការការពារពូជថ្មីនៃដំណាំ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

ច្បាប់នេះមានគោលបំណង ធានានូវការគ្រប់គ្រង ការលើកទឹកចិត្ត និង ការអភិវឌ្ឍពូជដំណាំដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និង បរិស្ថាន ។

**មាត្រា ៣.–**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ពូជដំណាំ រួមទាំងពូជដំណាំដែលមានស្រាប់ និង ពូជថ្មីនៃដំណាំ លើកលែងតែការគ្រប់គ្រង ដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៤.–**

ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ការគ្រប់គ្រងពូជដំណាំគ្រប់ប្រភេទ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥.–**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## ការការពារពូជថ្មីនៃដំណាំ

### ផ្នែកទី ១
### លក្ខខណ្ឌសម្រាប់ការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ

**មាត្រា ៦.-**

ពូជថ្មីនៃដំណាំដែលទទួលបាននូវសិទ្ធិការពារត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម:

-ភាពថ្មី

-ភាពខុសប្លែក

-ឯកសណ្ឋានភាព

-ស្ថេរភាព ។

**មាត្រា ៧.-**

ពូជដំណាំ ដែលអាចចាត់ទុកថាថ្មី លុះត្រាតែពុំទាន់បានដាក់លក់ ឬ ចរាចរលើទីផ្សារកន្លងមក ប៉ុន្តែដោយមានការឯកភាពពីអ្នកបង្កាត់ពូជ ពូជថ្មីនៃដំណាំនោះត្រូវបានដាក់លក់ ឬ ចរាចរលើទីផ្សារ ក្នុងរយៈពេលមិនលើសពី ១ (មួយ)ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង មិនលើសពី ៦(ប្រាំមួយ)ឆ្នាំ ចំពោះដំណាំវល្លិ និងដំណាំឈើ និងមិនលើសពី ៤(បួន) ឆ្នាំ ចំពោះគ្រប់ដំណាំផ្សេងៗទៀត នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដោយគិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំសិទ្ធិការពារ ។

**មាត្រា ៨.-**

ពូជដំណាំដែលចាត់ទុកថាមានភាពខុសប្លែកពីគេ លុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀត ដែលគេស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំសិទ្ធិ ឬ កាលបរិច្ឆេទសិទ្ធិអាទិភាព ។

ROYAUME DU CAMBODGE

**មាត្រា ៩.–**

ពូជដំណាំ ដែលចាត់ទុកថាមានឯកសណ្ឋានភាព លុះត្រាតែអាចរក្សាឯកសណ្ឋានភាពគ្រប់គ្រាន់នូវចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជ ទោះបីពូជដំណាំនោះ ត្រូវបានផលិតតាមរយៈភេទ ឬ អភេទក្តី ។

**មាត្រា ១០.–**

ពូជដំណាំ ដែលចាត់ទុកថាមានស្ថេរភាព លុះត្រាតែចរិតលក្ខណៈចាំបាច់របស់វាគ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់ និងជំនាន់នីមួយៗ ។

## ផ្នែកទី ២
## វិសាលភាព និងសុពលភាពនៃសិទ្ធិអ្នកបង្កាត់ពូជដំណាំ

**មាត្រា ១១.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានបង្កាត់ ឬ រកឃើញ និង អភិវឌ្ឍពូជថ្មីនៃដំណាំ ហើយមានបំណងការពារកម្មសិទ្ធិបញ្ញាលើពូជថ្មីនោះ ត្រូវដាក់ពាក្យស្នើសុំនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបញ្ជូនឯកសារនោះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីសិក្សាវាយតម្លៃអំពីលទ្ធផលបច្ចេកទេស ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់នេះ ។

វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវផ្តល់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រោយពីទទួលបានលិខិតបញ្ជាក់លទ្ធផលនៃការសិក្សាវាយតម្លៃលក្ខណៈបច្ចេកទេសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១២.–**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាស្ថាប័នទទួលខុសត្រូវក្នុងការចុះបញ្ជីការពារពូជថ្មីនៃដំណាំ មានតួនាទីដូចខាងក្រោម :

១-ផ្តល់ការការពារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំ

២-ផ្ទាស់ប្តូរម្ចាស់កម្មសិទ្ធិ

៣-ប្រកាសមោឃភាព ឬ លុបចោល

៤-ទទួលពាក្យចុះបញ្ជី ផ្លាស់ប្តូរ ឬ លុបចោលឈ្មោះពូជថ្មីនៃដំណាំ

៥-ចេញអាជ្ញាប័ណ្ណបញ្ជា និង

៦-កត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ ។

**មាត្រា ១៣.-**

អ្នកដាក់ពាក្យស្នើសុំការពារពូជថ្មីនៃដំណាំ ត្រូវ :

ក-មានសញ្ជាតិជាខ្មែរ ឬ សញ្ជាតិបរទេស ប៉ុន្តែត្រូវមាននិវេសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

ខ-មានទីលំនៅអចិន្ត្រៃយ៍នៅរដ្ឋជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ឬ នៅរដ្ឋណាមួយ ដែលមានបដិការយោគយល់គ្នាទៅវិញទៅមកជាមួយព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.-**

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំមានសិទ្ធិលក់ ឬ ផ្ទេរសិទ្ធិរបស់ខ្លួនបាន ។ ការលក់ ឬ ការផ្ទេរទៅឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយភាគីពាក់ព័ន្ធ ហើយត្រូវកត់ត្រានៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយត្រូវជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ១៥.-**

ការយកពូជ ឬ បំណែកពូជ ដែលបានការពារទៅប្រើប្រាស់ក្នុងសកម្មភាព ការផលិត ឬ ការផលិតឡើងវិញ ការកំណត់លក្ខខណ្ឌក្នុងគោលបំណងពង្រីកពូជ ការផ្គត់ផ្គង់សម្រាប់លក់ ការលក់ ឬ ការចែកចាយនៅលើទីផ្សារ ការនាំចេញ ការនាំចូល និង ការធ្វើសន្និធិ ត្រូវសុំការអនុញ្ញាតពីម្ចាស់សិទ្ធិ ។

ម្ចាស់សិទ្ធិ អាចផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ពូជដំណាំរបស់ខ្លួន ដោយភ្ជាប់នូវលក្ខខណ្ឌ ឬ ការកំណត់ផ្សេងៗ ។

ការធ្វើអាជីវកម្ម និង ប្រើប្រាស់ ដូចមានចែងក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះនូវផលិតផលដែលប្រមូលបានពីការដាំដុះពូជថ្មីនៃដំណាំ ដោយពុំមានការអនុញ្ញាត ត្រូវសុំ

ការអនុញ្ញាតពីម្ចាស់សិទ្ធិ ។ ម្ចាស់សិទ្ធិមានឱកាសសមស្របក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ។ នៅពេលម្ចាស់សិទ្ធិបានដឹងពីការប្រើប្រាស់ និង ធ្វើអាជីវកម្ម ដោយពុំមានការអនុញ្ញាត តែមិនបានប្រើប្រាស់សិទ្ធិរបស់ខ្លួន ម្ចាស់សិទ្ធិនឹងបាត់សិទ្ធិប្តឹងតវ៉ា ។

សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំក៏មានវិសាលភាពគ្របដណ្តប់ផងដែរទៅលើពូជ :

-ដែលបានបង្កើតថ្មី ដោយយកលក្ខណៈពិសេសសំខាន់ៗចេញពីពូជបានការពារ

-ដែលពុំមានភាពខុសគ្នាដាច់ស្រឡះ ពីពូជបានការពារ

-ដែលផលិតកម្មរបស់វាត្រូវការប្រើប្រាស់ឡើងវិញនូវពូជដែលបានការពារ ។

## មាត្រា ១៦.-

សិទ្ធិការពារពូជថ្មីនៃដំណាំ ពុំមានវិសាលភាពគ្របដណ្តប់ចំពោះករណីដូចខាងក្រោម :

១-ការប្រើប្រាស់ក្នុងគោលបំណងពិសោធន៍

២-ការដាំសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងគ្មានបំណងធ្វើពាណិជ្ជកម្ម

៣-ការប្រើប្រាស់ក្នុងគោលបំណងបង្កាត់ពូជដំណាំថ្មីផ្សេងទៀត លើកលែងតែវាក្យខណ្ឌទី ៤ មាត្រា ១៥ នៃច្បាប់នេះ ។

ដោយផ្អែកលើការការពារផលប្រយោជន៍ស្របច្បាប់ និង ព្រំដែនសិទ្ធិរបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចដាក់ចេញនូវបទប្បញ្ញត្តិដែលកម្រិតសិទ្ធិរបស់ម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំនានា ដើម្បីអនុញ្ញាតឱ្យកសិករផលិត និង ប្រើប្រាស់ជាសម្បត្តិផ្ទាល់ខ្លួននូវផលិតផលដែលប្រមូលផលបានពីការដាំដុះពូជថ្មីនៃដំណាំ ដែលបានការពារក្នុងគោលបំណងយកទៅដាំដុះបន្ត ។

## មាត្រា ១៧.-

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ត្រូវបាត់បង់សិទ្ធិចំពោះបំណែកពូជនៃពូជដែលទទួលបានការការពារ ឬ ពូជដំណាំដូចមានចែងក្នុងវាក្យខណ្ឌទី ៤ នៃមាត្រា ១៥ ដែលត្រូវបានដាក់លក់ ឬ ចរាចរនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់សិទ្ធិ ឬ មានការយល់

ព្រមពីម្ចាស់សិទ្ធិ ។ សិទ្ធិខាងលើនឹងមិនបាត់បង់ទេ ក្នុងករណីពូជ ឬ បំណែកពូជដែលយកចេញពីពូជដែលបានការពារ ត្រូវបានយកទៅពង្រីកពូជបន្ត ឬ នាំចេញទៅពង្រីកពូជក្នុងប្រទេសដែលមិនផ្តល់ការការពារ លើកលែងតែក្នុងគោលបំណងយកទៅប្រើប្រាស់ចុងក្រោយ ។

**មាត្រា ១៨.-**

ក្នុងរយៈពេលអនុវត្តសិទ្ធិ ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំមានកាតព្វកិច្ចផ្តល់សំណាកពូជដែលអាចដុះបាន ហើយមានចរិតលក្ខណៈដូចបានបញ្ជាក់ក្នុងសំណុំលិខិតស្នើសុំសិទ្ធិការពារ តាមតម្រូវការរបស់អង្គភាពមានសមត្ថកិច្ច ។

ក្នុងគោលបំណងថែរក្សាពូជថ្មីនៃដំណាំ ម្ចាស់សិទ្ធិក៏មានកាតព្វកិច្ចផ្តល់ព័ត៌មាននានាដែលពាក់ព័ន្ធនឹងពូជថ្មីនៃដំណាំ និង បង្កភាពងាយស្រួលក្នុងការត្រួតពិនិត្យដល់អង្គភាពមានសមត្ថកិច្ច ។

**មាត្រា ១៩.-**

សុពលភាពសិទ្ធិការពារលើពូជថ្មីនៃដំណាំមានរយៈពេល ២០(ម្ភៃ)ឆ្នាំ លើកលែងតែដំណាំដែលមានលក្ខណៈពិសេសដូចជាដំណាំវល្លិ និងដំណាំឈើ ដែលត្រូវមានរយៈពេល ២៥(ម្ភៃប្រាំ)ឆ្នាំ ក្រោយពីទទួលបានសិទ្ធិការពារលើពូជថ្មីនៃដំណាំនោះ ។

## ផ្នែកទី ៣

## ការបញ្ចប់ មោឃភាព និងការលុបចោល

**មាត្រា ២០.-**

សិទ្ធិការពារពូជថ្មីនៃដំណាំនឹងត្រូវបានបញ្ចប់មុនកាលបរិច្ឆេទផុតសុពលភាព ក្នុងករណីដែលម្ចាស់សិទ្ធិបោះបង់ចោលសិទ្ធិ ដោយធ្វើលិខិតជូនដំណឹងជាលាយល័ក្ខណ៍អក្សរជូនមន្ត្រីកាន់កាប់បញ្ជីនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

កាលបរិច្ឆេទនៃការបញ្ចប់ ត្រូវបញ្ជាក់ក្នុងលិខិតជូនដំណឹង ឬ បើគ្មានការកំណត់កាលបរិច្ឆេទសុំបញ្ចប់ច្បាស់លាស់ នៅក្នុងលិខិតជូនដំណឹងនោះទេ ត្រូវយកកាលបរិច្ឆេទដែលមន្ត្រីកាន់កាប់បញ្ជីទទួលបានលិខិតជូនដំណឹងនោះ ។

**មាត្រា ២១.–**

មន្ត្រីកាន់កាប់បញ្ជី ត្រូវប្រកាសជាមោឃភាពនូវសិទ្ធិរបស់ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ក្នុងករណីរកឃើញថា :

១-លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៧ ឬ មាត្រា ៨ នៃច្បាប់នេះមិនបាន បំពេញដូចកាលពីពេលផ្តល់សិទ្ធិ

២-លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៩ ឬ មាត្រា ១០ នៃច្បាប់នេះ មិនបាន បំពេញដូចកាលពីពេលផ្តល់សិទ្ធិ ដោយផ្អែកលើព័ត៌មាន និង ឯកសារដែលផ្តល់ដោយអ្នក បង្កាត់ពូជដំណាំ

៣-សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ ត្រូវបានផ្តល់ទៅឱ្យបុគ្គលដែលគ្មានសិទ្ធិទទួល ។

**មាត្រា ២២.–**

មន្ត្រីកាន់កាប់បញ្ជី ត្រូវលុបសិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ ក្នុងករណីដូចខាងក្រោម :

១-លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៩ ឬ មាត្រា ១០ នៃច្បាប់នេះ លែងបំពេញ បាន

២-ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ មិនបានអនុវត្តតាមការតម្រូវរបស់មន្ត្រីកាន់កាប់ បញ្ជី ដោយ :

ក-មិនបានផ្តល់នូវព័ត៌មាន ឯកសារ ឬ ពូជដំណាំ ដែលចាំបាច់សម្រាប់ ការផ្ទៀងផ្ទាត់

ខ-ខកខានមិនបានបង់កម្រៃ ដើម្បីរក្សាសិទ្ធិឱ្យនៅជាធរមាន ឬ

គ-មិនបានផ្តល់ឈ្មោះថ្មីសមស្រប បន្ទាប់ពីឈ្មោះពូជដំណាំដែល ទទួលបានសិទ្ធិការពារនោះ ត្រូវបានលុប ។

## ផ្នែកទី ៤
## ការដាក់ពាក្យ និង សិទ្ធិអាទិភាព

**មាត្រា ២៣.–**

អ្នកដាក់ពាក្យសុំការពារពូជថ្មីនៃដំណាំ ត្រូវដាក់ពាក្យជូនមន្ត្រីកាន់កាប់បញ្ជីតាមគំរូ ពាក្យសុំដែលបានកំណត់ ។

៩

អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ ឯកសារ ឬ ពូជដំណាំ តាមកាលបរិច្ឆេទ និង ទីកន្លែង ដែលកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ។

មន្ត្រីកាន់កាប់បញ្ជី ត្រូវចុះកាលបរិច្ឆេទទទួលពាក្យស្នើសុំ បន្ទាប់ពីបានបង់កម្រៃរួច ។

គំរូពាក្យស្នើសុំ ឯកសារ ឬ ពូជដំណាំនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ២៤.-**

អ្នកដាក់ពាក្យស្នើសុំ អាចប្រើប្រាស់សិទ្ធិអាទិភាពនៃពាក្យស្នើសុំលើកដំបូងនៅបរទេស សម្រាប់ពូជដំណាំដូចគ្នានៅប្រទេសណាមួយដែលជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ។

ក្នុងករណីមានពាក្យស្នើសុំច្រើននៅច្រើនប្រទេស សិទ្ធិអាទិភាពនឹងត្រូវផ្តល់ចំពោះតែការដាក់ពាក្យស្នើសុំលើកដំបូងបង្អស់ ។

អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់សិទ្ធិអាទិភាពឱ្យបានច្បាស់លាស់ក្នុងពាក្យស្នើសុំដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ហើយសិទ្ធិអាទិភាពត្រូវមានរយៈពេល ១២(ដប់ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យលើកដំបូងបង្អស់ ។

**មាត្រា ២៥.-**

ដើម្បីប្រើប្រាស់សិទ្ធិអាទិភាពរបស់ខ្លួនបាន អ្នកដាក់ពាក្យស្នើសុំត្រូវប្រគល់ឯកសារចម្លងនៃសំណុំលិខិតស្នើសុំដែលបានដាក់ដំបូងបង្អស់ចំនួនមួយច្បាប់ និង ត្រូវមានការបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម ដោយការិយាល័យដែលបានទទួលសំណុំលិខិតស្នើសុំដំបូងបង្អស់ក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំនៅព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រីកាន់កាប់បញ្ជី អាចផ្តល់ពេលវេលាសមស្របបន្ថែម សម្រាប់ការផ្តល់ព័ត៌មាន ឯកសារ ឬ ពូជដំណាំ តាមការស្នើសុំ ។

ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌតម្រូវក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះមិនបានបំពេញត្រឹមត្រូវទេនោះ ការទាមទារសិទ្ធិអាទិភាពត្រូវចាត់ទុកថាមិនបានធ្វើឡើយ ។

## ផ្នែកទី ៥
## ការដាក់ឈ្មោះពូជដំណាំ និងការប្រើប្រាស់

**មាត្រា ២៦.-**

អ្នកដាក់ពាក្យសុំ ត្រូវដាក់ឈ្មោះពូជដំណាំស្របទៅតាមបទប្បញ្ញត្តិនៃផ្នែកនេះ ។

ឈ្មោះពូជថ្មីនៃដំណាំ ត្រូវចាត់ទុកថាមិនសមស្រប ក្នុងករណីដូចខាងក្រោម :

ក-មិនអាចសម្គាល់ពូជដំណាំបាន

ខ-មានសញ្ញាតែមួយ លើកលែងតែសញ្ញានោះ អាចសម្គាល់ពូជដំណាំបាន

គ-នាំឱ្យសាធារណជនយល់ខុស ឬ បណ្តាលឱ្យភ័ន្តច្រឡំទៅនឹងចរិតលក្ខណៈ ឬ តម្លៃ ឬ អត្តសញ្ញាណនៃពូជដំណាំ ឬ អត្តសញ្ញាណរបស់អ្នកបង្កាត់ពូជ

ឃ-ដូចទៅនឹងឈ្មោះពូជដំណាំ ដែលមានរួចហើយក្នុងប្រភេទដំណាំតែមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋជាភាគីហត្ថលេខី

ង-ដូចទៅនឹងឈ្មោះពូជដំណាំ ដែលទទួលបានសិទ្ធិមុន ។

មានតែឈ្មោះដែលបានប្រើក្នុងការស្នើសុំ ឬ ចុះបញ្ជី នៅរដ្ឋជាភាគីហត្ថលេខីទេ ដែលត្រូវប្រើសម្រាប់ការស្នើសុំ ឬ ចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា លើកលែងតែឈ្មោះ ដែលមានន័យមិនសមស្របតាមប្រពៃណីវប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជា អ្នកកាន់កាប់បញ្ជីអាចតម្រូវឱ្យផ្តល់ឈ្មោះថ្មីបាន ។

**មាត្រា ២៧.-**

បុគ្គលធ្វើអាជីវកម្មពូជថ្មីនៃដំណាំ ដែលទទួលបានសិទ្ធិការពារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់ឈ្មោះពូជដំណាំដែលបានចុះបញ្ជី ទោះបីជាសិទ្ធិការពារផុតសុពលភាពក៏ដោយ លើកលែងតែសិទ្ធិដែលទទួលបានមុនណាមួយរារាំងដល់ការប្រើប្រាស់បែបនេះ ។

ពាណិជ្ជសញ្ញា ពាណិជ្ជនាម ឬ ការបញ្ជាក់ប្រហាក់ប្រហែលផ្សេងទៀត អាចភ្ជាប់ជាមួយឈ្មោះពូជថ្មីនៃដំណាំដែលបានការពារនៅពេលដែលពូជនោះត្រូវបានធ្វើអាជីវកម្ម ។

ROYAUME DU CAMBODGE · ROYAL

**មាត្រា ២៨.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវលុបឈ្មោះពូជដំណាំដែលបានចុះបញ្ជីរួចហើយ ប្រសិនបើឈ្មោះនោះមិនគួរត្រូវបានចុះបញ្ជី ។ ករណីនេះ ម្ចាស់សិទ្ធិត្រូវស្នើឈ្មោះថ្មីសមស្រប ដើម្បីចុះបញ្ជី ។

**មាត្រា ២៩.-**

ត្រូវបានហាមឃាត់ :

-ធ្វើអាជីវកម្មពូជថ្មីនៃដំណាំ ដែលទទួលបានសិទ្ធិការពារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រើប្រាស់ឈ្មោះដែលបានចុះបញ្ជី ដោយចេតនា

-ធ្វើអាជីវកម្មពូជថ្មីនៃដំណាំ ដែលទទួលបានសិទ្ធិការពារក្នុងព្រះរាជាណាចក្រកម្ពុជាលើពូជផ្សេងទៀតនៃដំណាំក្នុងប្រភេទដំណាំតែមួយ ដោយចេតនា ។

## ផ្នែកទី ៦
## ការពិនិត្យពាក្យស្នើសុំ និងការបោះពុម្ពផ្សាយ

**មាត្រា ៣០.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យពាក្យសុំដើម្បីកំណត់ថា បានបំពេញនូវលក្ខខណ្ឌនៃភាពថ្មី ភាពខុសប្លែក ឯកសណ្ឋានភាព និង ស្ថេរភាព ។ នៅពេលដែលលក្ខខណ្ឌទាំងនោះមិនត្រូវបានបំពេញ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធពាក្យស្នើសុំ ។

ក្នុងគោលបំណងកំណត់ភាពខុសប្លែក ឯកសណ្ឋានភាព និង ស្ថេរភាព មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនសំណុំឯកសារទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសិក្សាវាយតម្លៃអំពីលទ្ធផលបច្ចេកទេស ។

នៅពេលការសិក្សាវាយតម្លៃលទ្ធផលបច្ចេកទេស បង្ហាញលទ្ធផលវិជ្ជមាន និងការស្នើដាក់ឈ្មោះពូជដំណាំអាចចុះបញ្ជីបាន មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ហើយត្រូវបោះពុម្ពវិញ្ញាបនបត្របញ្ជាក់សិទ្ធិនោះនៅក្នុងព្រឹត្តិបត្រផ្លូវការ ។

ROYAUME DU CAMBODGE ... ROYAL

នៅពេលដែលការត្រួតពិនិត្យបង្ហាញថា ការស្នើសុំដាក់ឈ្មោះពូជដំណាំមិនអាចចុះបញ្ជីបាន មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យផ្តល់ឈ្មោះផ្សេងទៀតក្នុងរយៈពេលមិនលើសពី៣(បី)ខែ ។ ក្នុងករណីអ្នកដាក់ពាក្យខកខានមិនបានបំពេញតាមលក្ខខណ្ឌនេះទេ ត្រូវបដិសេធពាក្យសុំនោះ ។

នៅពេលដែលវិញ្ញាបនបត្របញ្ជាក់សិទ្ធការពារពូជថ្មីនៃដំណាំត្រូវបានផ្តល់ ម្ចាស់សិទ្ធិមានសិទ្ធិទាមទារសំណងសមស្រប ចំពោះសកម្មភាពទាំងឡាយណាដូចមានចែងក្នុងវាក្យខណ្ឌទី ១ មាត្រា ១៥ នៃច្បាប់នេះ ក្នុងចន្លោះពេលពីការបោះពុម្ពផ្សាយនៃពាក្យស្នើសុំរហូតដល់ការផ្តល់សិទ្ធិ ។

**មាត្រា ៣១.-**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបោះពុម្ពផ្សាយព័ត៌មានចាំបាច់ពាក់ព័ន្ធទៅនឹងការការពារពូជថ្មីនៃដំណាំនៅក្នុងព្រឹត្តិបត្រផ្លូវការ ។

## ផ្នែកទី ៧
## បណ្តឹងជំទាស់ និង បណ្តឹងឧបាស្រ័យ

**មាត្រា ៣២.-**

បុគ្គលដែលពាក់ព័ន្ធអាចដាក់ពាក្យប្តឹងជំទាស់ ចំពោះការការពារពូជថ្មីនៃដំណាំទៅកាន់មន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៣(បី)ខែ បន្ទាប់ពីលទ្ធផលនៃការពិនិត្យ ត្រូវបានបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

**មាត្រា ៣៣.-**

បុគ្គលណាដែលមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជីក្នុងការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ អាចធ្វើបណ្តឹងឧបាស្រ័យចំពោះការសម្រេចនោះ ទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ផ្នែកទី ៨
## អាជ្ញាប័ណ្ណ និង អាជ្ញាប័ណ្ណបញ្ញា

**មាត្រា ៣៤.-**

អ្នកដាក់ពាក្យសុំការពារសិទ្ធិ ឬ ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ អាចប្រគល់ទៅឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលផ្សេងទៀតនូវអាជ្ញាប័ណ្ណផ្តាច់មុខ ឬ អាជ្ញាប័ណ្ណមិនផ្តាច់មុខ ទាក់ទងទៅនឹងសិទ្ធិទាំងអស់ ឬ សិទ្ធិណាមួយ ដែលបានផ្តល់ជូនតាមច្បាប់នេះ ។

**មាត្រា ៣៥.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល អាចដាក់ពាក្យស្នើសុំមករដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យផ្តល់អាជ្ញាប័ណ្ណបញ្ញាក្នុងការប្រើប្រាស់ពូជថ្មីនៃដំណាំ ដោយផ្អែកលើមូលហេតុនៃភាពចាំបាច់ ដើម្បីការពារផលប្រយោជន៍សាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ញាស្របតាមមាត្រានេះ ត្រូវបង់ប្រាក់សំណងសមស្របទៅឱ្យម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ ។

## ផ្នែកទី ៩
## បទបញ្ជា និងការបង់កម្រៃ

**មាត្រា ៣៦.-**

បទបញ្ជានៃការអនុវត្តជំពូកទី ២ នៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣៧.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវបង់កម្រៃរដ្ឋបាលនៃការចុះបញ្ជី និងកម្រៃរក្សាសុពលភាពប្រចាំឆ្នាំនៃសិទ្ធិការ-ការពូជថ្មីនៃដំណាំ នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលស្នើសុំការសិក្សាវាយតម្លៃលក្ខណៈបច្ចេកទេសពូជថ្មីនៃដំណាំ ត្រូវបង់កម្រៃសេវាកម្មបច្ចេកទេស នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

កម្រៃរដ្ឋបាលពាក់ព័ន្ធក្នុងការចុះបញ្ជី កម្រៃរក្សាសុពលភាពប្រចាំឆ្នាំនៃសិទ្ធិការពារពូជថ្មីនៃដំណាំ និងកម្រៃសេវាកម្មបច្ចេកទេស ដែលមានចែងនៅក្នុងវាក្យខណ្ឌទី ១ និងវាក្យខណ្ឌទី ២ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី ១០

## ភ្នាក់ងារ

**មាត្រា ៣៨.-**

អ្នកបង្កាត់ពូជដំណាំ អាចដាក់ពាក្យស្នើសុំដោយខ្លួនឯង ឬ ភ្នាក់ងារ តំណាងមកដាក់ពាក្យស្នើសុំជំនួសខ្លួនបាន ។

ក្នុងករណីដែលមានទីលំនៅអចិន្ត្រៃយ៍ ឬ ទីតាំងប្រកបអាជីវកម្មរបស់អ្នកស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះ ត្រូវមានភ្នាក់ងារតំណាងដែលមានទីលំនៅអចិន្ត្រៃយ៍ ឬ កំពុងប្រកបវិជ្ជាជីវៈ នៅព្រះរាជាណាចក្រកម្ពុជា ។

ភ្នាក់ងារតំណាង ដែលដាក់ពាក្យស្នើសុំចុះបញ្ជីពូជថ្មីនៃដំណាំក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងបំពេញបានលក្ខខណ្ឌ ដូចមានចែងក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ជំពូកទី ៣

## ការគ្រប់គ្រងពូជដំណាំ

## ផ្នែកទី ១

## បញ្ជីពូជដំណាំរបស់ជាតិ

**មាត្រា ៣៩.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំឱ្យមានបញ្ជីពូជដំណាំរបស់ជាតិ រួមមានទាំងពូជដែលមានស្រាប់ និងពូជថ្មីនៃដំណាំ ។

ROYAUME DU CAMBODGE

**មាត្រា ៤០.-**

ពូជដំណាំដែលមានស្រាប់ អាចចុះក្នុងបញ្ជីពូជដំណាំរបស់ជាតិបាន ត្រូវផ្អែកលើលក្ខខណ្ឌជាអាទិ៍ ដូចខាងក្រោម :

១-មានឈ្មោះសម្គាល់ជាក់លាក់ ដោយបង្ការកុំឱ្យភាន់ច្រឡំជាមួយប្រភេទពូជដំណាំមួយផ្សេងទៀតដែលបានចុះបញ្ជីរួចហើយ ឬ បង្ការកុំឱ្យយល់ខុសចំពោះចរិតលក្ខណៈនៃពូជដំណាំនោះ

២-រក្សាទុកឈ្មោះដើមរបស់ពូជដំណាំ ក្នុងករណីជាពូជនាំចូលពីបរទេស

៣-មានភាពខុសគ្នាពីពូជដំណាំ ដែលបានចុះបញ្ជីរួចហើយ

៤-មានឯកសណ្ឋានភាពគ្រប់គ្រាន់ខាងចរិតលក្ខណៈប្រកបដោយស្ថេរភាព និងអាចធ្វើអត្តសញ្ញាណកម្មពូជបាន

៥-មានទិន្នន័យសាកល្បងច្បាស់លាស់ ធានាដោយមន្ទីរពិសោធន៍អង្គភាពជំនាញ គ្រឹះស្ថានស្រាវជ្រាវសាធារណៈ ឬ ផ្នែកឯកជនធ្វើសេវាកម្មបច្ចេកទេសពូជដំណាំ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី ២
## វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ

**មាត្រា ៤១.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងផលិតពូជដំណាំសម្រាប់ផ្គត់ផ្គង់លក់ ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គំរូពាក្យស្នើសុំ និង នីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព ពូជដំណាំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

កម្រៃសេវាកម្មក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE

## ផ្នែកទី ៣
## អាជីវកម្មពូជដំណាំ

**មាត្រា ៤២.-**

ការធ្វើអាជីវកម្មពូជដំណាំ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការផ្ទេរសិទ្ធិទៅឱ្យបុគ្គលដទៃនូវលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មពូជដំណាំ ត្រូវមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៣.-**

មន្ទីរពិសោធន៍ពូជដំណាំ ដែលស្ថិតក្រោមកម្មវត្ថុធ្វើអាជីវកម្មពូជដំណាំ ត្រូវមានអ្នកបច្ចេកទេសជំនាញកសិកម្មក្សេត្រវិទ្យា ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៤.-**

ហាមឃាត់ការចរាចរណ៍លើទីផ្សារនូវពូជដំណាំទាំងឡាយណាដែល ៖

១-មិនមានការវេចខ្ចប់ ការវេចខ្ចប់មិនបានត្រឹមត្រូវ ឬ ក្លែងបន្លំសំបកវេចខ្ចប់

២-ហួសរយៈពេលកំណត់នៃការប្រើប្រាស់

៣-មិនបានបំពេញត្រឹមត្រូវនូវព័ត៌មានបញ្ជាក់លើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា

៤-មិនមានស្លាកសញ្ញាស្របតាមការកំណត់ក្លែងបន្លំស្លាកសញ្ញា ឬ ខូចខាតស្លាកសញ្ញា ។

ព័ត៌មានបញ្ជាក់លើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៤
## ការត្រួតពិនិត្យគុណភាពពូជដំណាំ

**មាត្រា ៤៥.–**

ពូជដំណាំ ដែលអនុញ្ញាតឱ្យធ្វើអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ត្រូវតែជាពូជដំណាំមានគុណភាព និង ត្រូវឆ្លងកាត់ការធ្វើពិសោធន៍ ឬ ការដាំសាកល្បងដោយអង្គភាពជំនាញគ្រឹះស្ថានស្រាវជ្រាវសាធារណៈ ឬ ផ្នែកឯកជនធ្វើសេវាកម្មបច្ចេកទេសពូជដំណាំ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៦.–**

ការសិក្សាសាកល្បង ការយកសំណាក ការចាត់ថ្នាក់ ការកំណត់ស្តង់ដារគុណភាពពូជដំណាំ និង នីតិវិធីនៃការត្រួតពិនិត្យលើគុណភាពពូជដំណាំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៧.–**

លទ្ធផលនៃការសាកល្បងពូជដំណាំណាដែលមិនបានបំពេញតាមលក្ខខណ្ឌនៃស្តង់ដារគុណភាពពូជដំណាំ ត្រូវធ្វើចំណាត់ថ្នាក់ជាថ្មីក្រោមការត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ពូជដំណាំនោះមិនអាចដាក់តាំងលក់ជាពូជបានឡើយ ។

**មាត្រា ៤៨.–**

អ្នកផលិតពូជដំណាំ និងអ្នកលក់ពូជដំណាំ ត្រូវទទួលខុសត្រូវចំពោះអ្នកប្រើប្រាស់នូវគុណភាពពូជដំណាំរបស់ខ្លួនទៅតាមព័ត៌មានដែលមានបញ្ជាក់លើសំបកវេចខ្ចប់ ឬស្លាកសញ្ញា ។

**មាត្រា ៤៩.–**

ក្នុងករណីអ្នកប្រើប្រាស់ពូជដំណាំមានមន្ទិលសង្ស័យពីការក្លែងបន្លំគុណភាពពូជដំណាំដែលបានទិញ អ្នកប្រើប្រាស់អាចស្នើសុំបញ្ជាក់ជាលាយលក្ខណ៍អក្សរពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ROYAUME DU CAMBODGE

ការតវ៉ា ដែលទាក់ទងនឹងគុណភាពពូជដំណាំ ត្រូវធ្វើឡើងក្នុងរយៈពេល៣០(សាមសិប)ថ្ងៃក្រោយពេលទិញ តែមុនពេលយកទៅសាប បណ្តុះ ឬ ដាំ ។ ការតវ៉ាទាក់ទងនឹងចរិតលក្ខណៈ ឬ ការប្រែប្រួលពន្ធុ ត្រូវធ្វើឡើងចាប់ពីពេលទិញរហូតដល់មុនពេលប្រមូលផល ។

នីតិវិធីដោះស្រាយការតវ៉ា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥០.–**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិព្យួរ ដកហូត ឬ លុបចោលលិខិតអនុញ្ញាតធ្វើអាជីវកម្ម និង វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ក្នុងករណីជាអាទិ៍ដូចខាងក្រោម :

១-លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញពីផលប៉ះពាល់ធ្ងន់ធ្ងរជាយថាហេតុដល់សុខភាពមនុស្ស សត្វ និង បរិស្ថាន បណ្តាលមកពីឥទ្ធិពលនៃការប្រើប្រាស់ពូជដំណាំនោះ

២-ពូជដំណាំ ដែលបានធ្វើអាជីវកម្មមានគុណភាពខុសពីពូជដំណាំដែលបានបញ្ជាក់ក្នុងវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ឬ លើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា

៣-អ្នកកាន់លិខិតអនុញ្ញាតធ្វើអាជីវកម្ម និង វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំមិនគោរពតាមលក្ខខណ្ឌដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៤

## អាហរណកម្ម នីហរណកម្ម និងការដឹកជញ្ជូនឆ្លងកាត់

### ផ្នែកទី ១

### អាហរណកម្ម និង នីហរណកម្ម

**មាត្រា ៥១.–**

ការនាំចេញ នាំចូលពូជដំណាំ រួមទាំងការសាកល្បង ការសិក្សា និងការពិសោធត្រូវ

ROYAUME DU CAMBODGE

មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការផ្ទេរសិទ្ធិទៅឱ្យ បុគ្គលដទៃនូវលិខិតអនុញ្ញាតនាំចេញ នាំចូលពូជដំណាំ ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥២.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលនាំចូលពូជដំណាំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម :

១-ធ្វើប្រតិវេទន៍ទំនិញឱ្យ បានត្រឹមត្រូវ

២-មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ចេញដោយសមត្ថកិច្ចនៃប្រទេសនាំចេញ

៣-មានលិខិតអនុញ្ញាតឱ្យនាំចូលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤-ជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យ៉ាងតិច ១០ (ដប់)ថ្ងៃនៃថ្ងៃធ្វើការ មុនពេលពូជដំណាំមកដល់ច្រកទ្វារនាំចូលនៃព្រំដែនព្រះរាជាណាចក្រកម្ពុជា

៥-បំពេញលក្ខខណ្ឌភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៣.-**

ការនាំចូលពូជដំណាំដែលបង្កគ្រោះថ្នាក់ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់ដាច់ខាត ។

បញ្ជីឈ្មោះពូជដំណាំដែលបង្កគ្រោះថ្នាក់ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៤.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដកហូតលិខិតអនុញ្ញាត និង បញ្ឈប់ការនាំចេញ នាំចូលពូជដំណាំ ក្នុងករណីរកឃើញថាពូជដំណាំនោះមិនស្របតាមស្តង់ដារគុណភាពពូជដំណាំ ។

ROYAUME DU CAMBODGE ... ROYAL

**មាត្រា ៥៥.-**

ផលិតផលដំណាំដែលបាននាំចូល ដើម្បីបម្រើឧស្សាហកម្ម ការប្រើប្រាស់ ឬ គោលបំណងផ្សេងៗទៀត មិនអនុញ្ញាតឱ្យយកទៅប្រើប្រាស់ជាពូជដំណាំបានឡើយ ។

**មាត្រា ៥៦.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលនាំចេញពូជដំណាំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម :

១-ធ្វើប្រតិវេទន៍ទំនិញឱ្យបានត្រឹមត្រូវ

២-ត្រូវមានលិខិតអនុញ្ញាតឱ្យនាំចេញពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

៣-ត្រូវជូនដំណឹងមកភ្នាក់ងារភូតគាមអនាម័យដែលនៅជិតបំផុត យ៉ាងតិច ១(មួយ)ថ្ងៃនៃថ្ងៃធ្វើការ មុនពេលពូជដំណាំមកដល់ច្រកទ្វារនាំចេញនៃព្រះរាជាណាចក្រកម្ពុជា

៤-មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ

៥-បំពេញលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល ។

**មាត្រា ៥៧.-**

ក្នុងករណីមានការចាំបាច់ ដើម្បីផលប្រយោជន៍ជាតិ ឬ សាធារណៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអំណាចផ្អាកជាបណ្តោះអាសន្ន ឬ ស្ថាពរ នូវការនាំចេញពូជដំណាំពីព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ២

## ការដឹកជញ្ជូនឆ្លងកាត់

**មាត្រា ៥៨.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលដឹកជញ្ជូនពូជដំណាំឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម :

១-ធ្វើប្រតិវេទន៍ទំនិញឱ្យបានត្រឹមត្រូវ

២-មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំចេញដោយសមត្ថកិច្ចនៃ

ROYAUME DU CAMBODGE - ROYAL

ប្រទេសនាំចេញ

៣-ត្រូវជូនដំណឹងយ៉ាងតិច ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ មុនពេលពូជដំណាំមកដល់ច្រកទ្វារនាំចូល ដោយបញ្ជាក់កាលបរិច្ឆេទ និង ច្រកទ្វារនាំចេញមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤-ធានាគុណភាពសុវត្ថិភាពនៃសំបករវេចខ្ចប់ មធ្យោបាយផ្ទុកពូជដំណាំ និងអនាម័យនៃមធ្យោបាយដឹកជញ្ជូន

៥-ពុំមានចម្លងមកជាមួយនូវសមាសភាពចង្រៃភូតគាមអនាម័យ និងបណ្តាសមាសភាពចង្រៃបង្កគ្រោះថ្នាក់ដទៃទៀតដែលអាចឆ្លងរាលដាលនៅតាមផ្លូវដឹកជញ្ជូនឆ្លងកាត់ ។

**មាត្រា ៥៩.-**

ក្នុងពេលដឹកជញ្ជូនឆ្លងកាត់ ប្រសិនបើមានរបើកស្លាកសុវត្ថិភាព ធ្លុះធ្លាយកុងតឺន័រ ឬ សម្ភារៈវេចខ្ចប់ ម្ចាស់ពូជដំណាំ ឬ អ្នកតំណាងទទួលខុសត្រូវ ត្រូវរាយការណ៍ជាបន្ទាន់មកភ្នាក់ងារភូតគាមអនាម័យដែលនៅជិតបំផុត និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការសមស្រប ។

**មាត្រា ៦០.-**

ភ្នាក់ងារភូតគាមអនាម័យ ត្រូវធ្វើការត្រួតពិនិត្យអនាម័យនៃមធ្យោបាយដឹកជញ្ជូន រួមទាំងផ្ទៃខាងក្រៅនៃមធ្យោបាយផ្ទុកទំនិញ និង វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំរបស់ប្រទេសនាំចេញ ព្រមទាំងលិខិតពាក់ព័ន្ធនានា ហើយត្រូវសម្រួលឱ្យការដឹកជញ្ជូនបន្តបានឆាប់រហ័ស ។

## ជំពូកទី ៥

## មូលនិធិជាតិអភិវឌ្ឍពូជដំណាំ

**មាត្រា ៦១.-**

រាជរដ្ឋាភិបាលអាចបង្កើតមូលនិធិមួយហៅថា “ **មូលនិធិជាតិអភិវឌ្ឍពូជដំណាំ** ” ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីទ្រទ្រង់ដល់ការស្រាវជ្រាវ និងអភិវឌ្ឍពូជដំណាំក្នុង

ROYAUME DU CAMBODGE

គោលដៅលើកកម្ពស់ផលិតភាពកសិកម្ម។

មូលនិធិជាតិអភិវឌ្ឍពូជដំណាំ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦២.-**

មូលនិធិជាតិអភិវឌ្ឍពូជដំណាំ មានប្រភពចំណូលពី :

១-ថវិកាអំណោយ ឬវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាលសម្រាប់គោលបំណងស្រាវជ្រាវ និង អភិវឌ្ឍពូជដំណាំ

២-អំណោយពីសប្បុរសជន សមាគម អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា

៣-ប្រាក់ពិន័យអន្តរការណ៍លើបទល្មើសពូជដំណាំ

៤-កម្រៃសេវាកម្មផ្សេងៗក្នុងវិស័យពូជដំណាំ ។

ថវិកា និង រាល់ចំណូលរបស់មូលនិធិជាតិអភិវឌ្ឍពូជដំណាំ ត្រូវបង់ចូលគណនីមូលនិធិជាតិអភិវឌ្ឍពូជដំណាំ ។

**មាត្រា ៦៣.-**

មូលនិធិជាតិអភិវឌ្ឍពូជដំណាំ អាចប្រើប្រាស់បានចំពោះសកម្មភាពដូចខាងក្រោម :

១-ការស្រាវជ្រាវបច្ចេកវិទ្យាជម្រើសពូជ

២-ការពិសោធ ឬ ការសាកល្បងពូជដំណាំ និង ការបង្កាត់ពូជដំណាំ

៣-ការផ្សព្វផ្សាយ អប់រំ និងបណ្តុះបណ្តាលបច្ចេកវិទ្យាពូជដំណាំ

៤-ការចូលរួមជាសមាជិកអង្គការអន្តរជាតិ ឬ តំបន់ក្នុងវិស័យពូជដំណាំ ។

រាជរដ្ឋាភិបាល អាចកំណត់គោលការណ៍លើកទឹកចិត្តដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានស្នាដៃក្នុងការបង្កើត កែលម្អ និងនាំមកនូវធនធានពន្ធុក៏ដូចជាការខិតខំអភិរក្សផលិត បង្កាត់ ពិសោធ សាកល្បង ជ្រើសរើស ការបញ្ចេញឱ្យប្រើ និង កែច្នៃពូជដំណាំ ។

# ជំពូកទី ៦

## ភ្នាក់ងារអធិការកិច្ចពូជដំណាំ

**មាត្រា ៦៤.-**

ភ្នាក់ងារអធិការកិច្ចពូជដំណាំនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសមត្ថកិច្ច និង បំពេញតួនាទីជាមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ។

បែបបទ និង នីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងមាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៥.-**

ភ្នាក់ងារអធិការកិច្ចពូជដំណាំ មានភារកិច្ច និងសិទ្ធិដូចខាងក្រោម :

១-តាមដាន និង ត្រួតពិនិត្យជាប្រចាំនូវការធ្វើអាជីវកម្មគ្រប់រូបភាពនិង គ្រប់សកម្មភាពពាក់ព័ន្ធពូជដំណាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-ធ្វើអធិការកិច្ចគ្រប់ទីតាំងអាជីវកម្មពូជដំណាំគ្រប់ប្រភេទ ឃ្លាំងស្តុក រោងចក្រ សហគ្រាស រួមទាំងកសិដ្ឋានដែលពាក់ព័ន្ធ ឬ សង្ស័យថាបានប្រព្រឹត្តល្មើសនឹងច្បាប់នេះ

៣-ដកយកសំណាកពូជដំណាំទាំងឡាយណា ដែលបានសង្ស័យថាល្មើសនឹងច្បាប់នេះ ដើម្បីធ្វើការពិសោធ

៤-តម្រូវឱ្យអាជីវករបង្ហាញនូវលិខិតអនុញ្ញាតពាក់ព័ន្ធ ឬ ឯកសារផ្សេងៗពាក់ព័ន្ធការធ្វើអាជីវកម្មពូជដំណាំ

៥-ដកហូតជាបណ្តោះអាសន្ននូវរាល់លិខិតអនុញ្ញាតគ្រប់ប្រភេទ ឬ ឯកសារពាក់ព័ន្ធ ក្នុងករណីអ្នកកាន់កាប់លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ

៦-ក្នុងករណីបទល្មើសជាក់ស្តែង មានសិទ្ធិឃាត់ ឬ បញ្ឈប់មធ្យោបាយដឹកជញ្ជូន ឬ មធ្យោបាយផ្ទុកពូជដំណាំ ដើម្បីត្រួតពិនិត្យ និង ឃាត់ទុកជាបណ្តោះអាសន្ននូវវត្ថុតាងនៃបទល្មើស និង មធ្យោបាយ ដើម្បីធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញា ។

ROYAUME DU CAMBODGE · ROYAL

**មាត្រា ៦៦.-**

ភ្នាក់ងារភូតគាមអនាម័យមានសមត្ថកិច្ច មានសិទ្ធិចូលរួមបំពេញភារកិច្ចនៅតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៧.-**

អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ ស្ថាប័នគយ និង រដ្ឋាករ ស្ថាប័នព្រលានយន្តហោះ កំពង់ផែ និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត ជួយសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសពូជដំណាំ ឬ ថែរក្សាវត្ថុតាងបទល្មើសពូជដំណាំជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីភ្នាក់ងារអធិការកិច្ចពូជដំណាំ ។

**មាត្រា ៦៨.-**

នៅពេលបំពេញបេសកកម្ម ភ្នាក់ងារអធិការកិច្ចពូជដំណាំ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ និង ត្រូវមានលិខិតបញ្ជាបេសកកម្ម ។

ឯកសណ្ឋាន និង សញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

### ផ្នែកទី ១

### បទល្មើសលើការការពារពូជថ្មីនៃដំណាំ

**មាត្រា ៦៩.-**

រាល់វិវាទ ដែលបានកើតឡើងពាក់ព័ន្ធទៅនឹងការអនុវត្តជំពូកទី ២ និង បទបញ្ញាទាំងឡាយ ត្រូវប្តឹងទៅមន្ត្រីកាន់កាប់បញ្ជីការពារពូជថ្មីនៃដំណាំ ។

មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់ឱកាសសម្រាប់សវនាការដល់ភាគីនៃបណ្តឹង នៅចំពោះមុខខ្លួន មុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិដែលបានប្រគល់ឱ្យដោយច្បាប់នេះ និងដោយបទបញ្ញាទាំងឡាយចំពោះភាគី ។

**មាត្រា ៧០.-**

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ អាចប្តឹងទៅតុលាការមានសមត្ថកិច្ចឱ្យជួសជុលសំណងតាមនីតិវិធី ដូចខាងក្រោម ៖

-ធ្វើបណ្តឹងរដ្ឋប្បវេណី ឬ ស្នើសុំដីកាបណ្តោះអាសន្ន ដើម្បីហាមឃាត់ការប្រព្រឹត្ត ឬ ការបន្តការប្រព្រឹត្តអំពើរំលោភបំពានលើសិទ្ធិអ្នកបង្កាត់ពូជដំណាំ

-ស្នើសុំការដាកពិន័យ ការរឹបអូស ឬ ការបំផ្លាញចោលពូជដំណាំ ដែលបានផលិតល្មើសលើសិទ្ធិអ្នកបង្កាត់ពូជដំណាំ និង

-ស្នើសុំឱ្យសងការខូចខាតជាទឹកប្រាក់ ។

**មាត្រា ៧១.-**

បុគ្គលណាមួយដែលផ្តល់ព័ត៌មានមិនពិតនៅក្នុងឯកសារ ដែលដាក់សុំការពារពូជថ្មីនៃដំណាំ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀលទៅ ៥.០០០.០០០ (ប្រាំលាន)រៀល ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ៦(ប្រាំមួយ)ខែ ឬ ត្រូវផ្តន្ទាទោសទាំងពីរខាងលើ ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៧២.-**

បុគ្គលណាមួយដែលរំលោភដោយចេតនាលើសិទ្ធិការពារពូជថ្មីនៃដំណាំដូចមានចែងក្នុងមាត្រា ១៥ ជំពូកទី ២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ ឬ ត្រូវផ្តន្ទាទោសទាំងពីរខាងលើ ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

AE DU CAMBODGE

**មាត្រា ៧៣.—**

ក្នុងករណីបុគ្គលណាមួយ ត្រូវបានផ្តន្ទាទោសតាមបញ្ញត្តិនៃផ្នែកនេះ តុលាការមានសមត្ថកិច្ច អាចបញ្ជាឱ្យធ្វើការរឹបអូសទុកជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោលនូវពូជដំណាំដែលរំលោភបំពាន វត្ថុតាង និង សម្ភារៈឧបករណ៍ ដែលយកមកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

## ផ្នែកទី ២
## បទល្មើសលើអាជីវកម្មពូជដំណាំ

**មាត្រា ៧៤.—**

ទណ្ឌកម្មក្នុងបទល្មើសអាជីវកម្មពូជដំណាំមាន : ពិន័យអន្តរការណ៍ ការឃាត់ទុកវត្ថុតាង ការរឹបអូសវត្ថុតាង ការបំផ្លាញវត្ថុតាង ការតម្រូវឱ្យជួសជុលការខូចខាត ការដកហូត ឬ ព្យួរលិខិតអនុញ្ញាតធ្វើអាជីវកម្ម លិខិតអនុញ្ញាតនាំចូល-នាំចេញពូជដំណាំ វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ទោសពិន័យ និង ទោសដាក់ពន្ធនាគារ ។

ការពិន័យអន្តរការណ៍លើបទល្មើសពូជដំណាំ ការឃាត់ទុកវត្ថុតាង ការដកហូតឬព្យួរលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម លិខិតអនុញ្ញាតនាំចូល-នាំចេញពូជដំណាំ និង វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ក្នុងករណីជនល្មើសមិនព្រមអនុវត្តតាមការសម្រេចរបស់សមត្ថកិច្ច ដូចមានចែងក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបញ្ជូនសំណុំរឿងប្តឹងទៅតុលាការ ។

ការរឹបអូស និង បំផ្លាញវត្ថុតាង ការជួសជុលលើការខូចខាត ទោសពិន័យ និងទោសដាក់ពន្ធនាគារ ជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៧៥.—**

បែបបទនៃការពិន័យអន្តរការណ៍ និង តម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់

ROYAUME du CAMBODGE ROYAL ព្រះរាជាណាចក្រកម្ពុជា

អនុវត្តការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៧៦.–**

ប្រាក់ពិន័យសម្រាប់ផ្តល់ជារង្វាន់លើកទឹកចិត្តដល់អ្នកមានស្នាដៃបង្ក្រាបបទល្មើស និងកម្រិតកំណត់សម្រាប់មូលនិធិជាតិអភិវឌ្ឍពូជដំណាំ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៧៧.–**

អ្នកកាន់កាប់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម លិខិតអនុញ្ញាតឱ្យនាំចេញ-នាំចូលពូជដំណាំណា ដែលផ្ទេរសិទ្ធិទៅឱ្យបុគ្គលដទៃ ដោយគ្មានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលពិន័យព្យួរលិខិតអនុញ្ញាតឱ្យនោះក្នុងរយៈពេលមួយឆ្នាំ ។

ក្នុងករណីមិនរាងចាល ត្រូវដកហូតជាស្ថាពរនូវលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ឬ លិខិតអនុញ្ញាតនាំចេញ-នាំចូលពូជដំណាំ និងត្រូវពិន័យអន្តរការណ៍ស្របតាមមាត្រា ៧៨ នៃច្បាប់នេះ ។

**មាត្រា ៧៨.–**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនពី ៥០០.០០០(ប្រាំសែន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម:

១-មិនធ្វើនិយតកម្មស្របតាមច្បាប់នេះនូវពូជដំណាំ ដែលបានចុះបញ្ជីក្រោមបទប្បញ្ញត្តិនានាក្នុងរយៈពេល៦ខែ (ប្រាំមួយខែ) ក្រោយច្បាប់នេះចូលជាធរមាន

២-គ្មានអ្នកបច្ចេកទេសជំនាញកសិកម្ម ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំការនៅមន្ទីរពិសោធន៍ពូជដំណាំរបស់ខ្លួន

៣-ធ្វើការនាំចេញ នាំចូល ឬ ដឹកជញ្ជូនពូជដំណាំឆ្លងកាត់ដោយ:

-មិនធ្វើប្រតិវេទន៍ទំនិញឱ្យ បានត្រឹមត្រូវ

-មិនជូនដំណឹងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-មិនរាយការណ៍ជាបន្ទាន់មកភ្នាក់ងារភូតគាមអនាម័យក្នុងពេលដឹកជញ្ជូនឆ្លងកាត់មានរបើកស្លាកសុវត្ថិភាព ធុះធ្លាយកុងតឺន័រ ឬ សម្ភារៈវេចខ្ចប់ ដើម្បីចាត់វិធានការសមស្រប

-មិនបានបំពេញលក្ខខណ្ឌភូតគាមអនាម័យ

-មិនមានការវេចខ្ចប់ត្រឹមត្រូវ ឬខូចខាតសម្ភារៈវេចខ្ចប់ ឬ ស្លាកសញ្ញា។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ទ្វេដង ឬ បញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៧៩.-**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២(ពីរ)ដង នៃតម្លៃវត្ថុតាងពិតប្រាកដលើទីផ្សារ ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ធ្វើអាជីវកម្មពូជដំណាំ ឬ នាំចូលពូជដំណាំដើម្បីធ្វើការសិក្សាពិសោធដោយគ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២-ធ្វើអាជីវកម្មពូជដំណាំ ដោយគ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ

៣-យកផលិតផលដែលបាននាំចូល ដើម្បីបម្រើឧស្សាហកម្ម ការប្រើប្រាស់ ឬ គោលបំណងផ្សេងៗទៀតទៅប្រើប្រាស់ជាពូជដំណាំ ឬ កែច្នៃ ដើម្បីប្រើប្រាស់ជាពូជដំណាំ

៤-ធ្វើការនាំចេញ ឬ នាំចូលពូជដំណាំដោយ :

-គ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-គ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ។

៥-ធ្វើការដឹកជញ្ជូនឆ្លងកាត់ ដោយគ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំចេញដោយសមត្ថកិច្ចនៃប្រទេសនាំចេញ

៦-ធ្វើអាជីវកម្ម ឬ ចរាចរលើទីផ្សារនូវពូជដំណាំដែល :

-ពុំមានគុណភាពទៅតាមព័ត៌មាន ដែលមានចែងលើសំបកវេចខ្ចប់ ឬ ស្លាកសញ្ញា

-ហួសរយៈពេលកំណត់នៃការប្រើប្រាស់

-មិនមានស្លាកសញ្ញា ស្របតាមការកំណត់ ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ទ្វេដង និងត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម លិខិតអនុញ្ញាតនាំចេញ-នាំចូល ឬវិញ្ញាបនបត្របញ្ជាក់គុណភាពដំណាំ ឬបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៨០.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និង ត្រូវពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ១០.០០០.០០០ (ដប់លាន)រៀល ឬ ត្រូវផ្តន្ទាទោសណាមួយនៃទោសទាំងពីរ និងត្រូវដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ បំផ្លាញចោលវត្ថុតាង ឬរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម :

១-នាំចូលពូជដំណាំចង្រៃបង្កគ្រោះថ្នាក់មកក្នុងព្រះរាជាណាចក្រកម្ពុជា

២-នាំចេញពូជដំណាំ ដោយបំពានបម្រាមរបស់រដ្ឋនៅពេលដែលព្រះរាជាណាចក្រកម្ពុជាមានតម្រូវការជាចាំបាច់

៣-ក្លែងបន្លំគុណភាពពូជដំណាំ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ដោយពុំទាន់គិតពីការទទួលខុសត្រូវរដ្ឋប្បវេណីថែមទៀត ក្នុងករណីមានផលប៉ះពាល់ដល់សុខភាពសាធារណៈ ឬ ខូចខាតកេរ្តិ៍បរិស្ថាន ។

## ផ្នែកទី ៣
## បទល្មើសដោយមន្ត្រីអនុវត្តច្បាប់

**មាត្រា ៨១.-**

ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល និង/ឬចោទប្រកាន់ចំពោះមុខតុលាការ ។

ROYAUME DU CAMBODGE • ROYAL • ព្រះរាជាណាចក្រ

ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីរូបណាដែលសមគំនិតនិងអ្នកប្រព្រឹត្តបទល្មើស ឬ ជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសនេះ ត្រូវផ្តន្ទាទោសដូចគ្នាដែរ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៨២.-**

ពូជដំណាំ ដែលទទួលបានវិញ្ញាបនបត្របញ្ជាក់គុណភាព និង លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មពូជដំណាំក្រោមបទប្បញ្ញត្តិផ្សេងៗ ត្រូវធ្វើនិយតកម្មស្របតាមច្បាប់នេះក្នុងរយៈពេលមិនលើសពី ៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៨៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨៤.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៥០៨.៥៣៤ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
ច័ន្ទ សារុន

លេខ: ៤៩៥ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០៨
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**
**ស៊ុន ជិនកេន**

# ឧបសម្ព័ន្ធ
# វាក្យស័ព្ទ

**ក -ការកែច្នៃពូជដំណាំ:** (Seed Processing)

សំដៅដល់ការសម្ងួត ការសម្អាត ប្រព្រឹត្តកម្ម និង ការវេចខ្ចប់ពូជដំណាំសម្រាប់ធ្វើការលក់ដូរ ។

**ខ -ការដឹកជញ្ជូនឆ្លងកាត់:** (Transit)

សំដៅដល់ការដឹកជញ្ជូនពូជដំណាំឆ្លងកាត់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ការដឹកជញ្ជូនឆ្លងកាត់នេះ មិនរាប់បញ្ចូលនូវការបើទំនិញ ការឈប់ ដើម្បីដាក់ទំនិញចូលក្នុងឃ្លាំង ការបើកសម្ភារៈវេចខ្ចប់ទំនិញ ឬ ការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូនឡើយ ។

**គ -ការត្រួតពិនិត្យពូជដំណាំ:** (Seed Inspection)

សំដៅដល់ការត្រួតពិនិត្យគុណភាព និងការយកសំណាកពូជដំណាំមកវិភាគ ការស្រាវជ្រាវ ការរុករក និង ការបង្ក្រាបបទល្មើស ។

**ឃ -ការសាកល្បង:** (Seed Testing)

សំដៅដល់ការងារពិសោធន៍តាមដាននៅក្នុងថ្នាលពិសោធន៍ និងវិភាគ គុណភាពពូជដំណាំ នៅក្នុងមន្ទីរពិសោធន៍ ។

**ង -ការបញ្ចេញឱ្យប្រើ:** (Release)

សំដៅដល់ការដល់វិដោះពូជដំណាំ ដើម្បីដាក់ឱ្យប្រើប្រាស់ជាសាធារណៈ ក្រោយពីបានយល់ព្រមពីគណៈកម្មការវាយតម្លៃបច្ចេកទេស ។

**ច -កុងតឺន័រ:** (Container)

សំដៅដល់ឧបករណ៍សម្រាប់ផ្ទុកទំនិញសម្រាប់ការដឹកជញ្ជូន ។

**ឆ -គុណភាពពូជដំណាំ:** (Seed Quality)

សំដៅដល់លក្ខណៈវិនិច្ឆ័យបច្ចេកទេសនៃពូជដំណាំ ដែលមានជាអាទិ៍: កម្រិតសំណើម

កម្រិតតដំណុះ ភាពសុទ្ធ សុខភាពពូជដំណាំ ។ល។

**ជ -ទីផ្សារពូជដំណាំ:** (Seed Marketing)

សំដៅដល់ការទិញ-លក់ ការចែកចាយ និង ការស្តុកពូជដំណាំ ។

**ឈ -នាយកដ្ឋានចុះបញ្ជីពូជថ្មីនៃដំណាំ:** (Registration Department)

សំដៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ញ -ពន្ធុ:** (Gene)

សំដៅដល់ក្រុមនៃក្រូម៉ូសូម ដែលជាឯកតាបន្តពូជអាចបញ្ជូនព័ត៌មានតំណពូជពីជំនាន់មួយទៅជំនាន់មួយក្រោយទៀត ឬ ពីមេបាទៅកូន ។

**ដ -ពូជ:** (Variety)

សំដៅដល់រាល់ប្រភេទពូជដំណាំ ឬ ក្រុមផ្សេងៗនៃប្រភេទពូជដំណាំណាមួយដែលមានលក្ខណៈដូចគ្នា និង ធ្វើឱ្យឃើញថាប្លែកពីរុក្ខជាតិដទៃទៀតក្នុងប្រភេទពូជដំណាំតែមួយក្នុងលក្ខណៈមួយ ឬ ច្រើន ហើយដែលលក្ខណៈទាំងនេះនៅតែអាចរក្សាបាន ដើម្បីយកទៅប្រើប្រាស់ធ្វើជាពូជដំណាំបាន ឬ ការបង្កាត់ដោយសរីរាង្គដទៃទៀត ។

**ឋ -ពូជដំណាំ:** (Seed)

សំដៅដល់រាល់មេជីវិតបន្តពូជ (អូវុលពេញវ័យ) ដែលមានបំណែកអំព្រីយ៉ុង សារធាតុចិញ្ចឹម និងសំបកការពារគ្រាប់ពូជ ឬ សរីរាង្គដាំដុះមួយដែលត្រូវបានយកទៅប្រើប្រាស់ក្នុងការសាប ការបណ្តុះ ឬ ការដាំសម្រាប់ផលិតកម្មដំណាំ ទោះបីជាការបន្តពូជនោះធ្វើឡើងដោយភេទក្តី ឬ អភេទក្តី ។ ដោយរួមបញ្ចូលនូវរាល់ចំណាត់ថ្នាក់នៃគ្រាប់ពូជដំណាំ ឬសរីរាង្គបន្តពូជ (ក្នុងនោះមានពូជដំណាំស្បៀង ដំណាំឧស្សាហកម្ម ដំណាំប្រេង ដំណាំចំណីសត្វ ឬ ផ្កា និងដំណាំលម្អនានា) និងរួមបញ្ចូលនូវកូនបណ្តុះ ឬ សំណាប ដើម ឫស បំណែករុក្ខជាតិ សរីរាង្គផ្សាំរុក្ខជាតិ ដែលបង្កាត់ដោយលក្ខណៈមីក្រូ និង រាល់បណ្តាសរីរាង្គបង្កាត់ដោយលក្ខណៈសរីរាង្គ ។

ROYAUME DU CAMBODGE ... ROYAL

**ខ-ពូជដំណាំដែលមានស្រាប់:** (Existing Variety)

សំដៅដល់ពូជដំណាំទាំងឡាយដែលកំពុងត្រូវបានប្រើប្រាស់ និង ធ្វើអាជីវកម្មទូទៅដោយពុំមានកម្មសិទ្ធិរបស់នរណាម្នាក់ ។

**គ-ពូជថ្មីនៃដំណាំ:** (New Variety)

សំដៅដល់ពូជដំណាំទាំងឡាយ ដែលទើបនឹងរកឃើញ និង អភិវឌ្ឍថ្មីៗ ដោយរុក្ខ-ជម្រើសវិទូ ឬ អ្នកបង្កាត់ពូជដំណាំ និងកាន់កាប់ផ្តាច់មុខយ៉ាងទូលំទូលាយក្នុងរយៈពេលមួយជាក់លាក់ ដែលកំណត់ដោយច្បាប់នេះ ។

**ឃ-ភាគីហត្ថលេខី:** (Contracting Party)

សំដៅប្រទេស ឬ អង្គការអន្តរជាតិ ដែលជាភាគីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ហៅកាត់ថាយូប៉ុវ (UPOV) ។

**ង-មន្ត្រីកាន់កាប់បញ្ជី:** (Registrar)

សំដៅប្រធាននាយកដ្ឋានចុះបញ្ជីនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ច-លក្ខខណ្ឌភូតគាមអនាម័យ:** (Phytosanitary Condition)

សំដៅដល់លក្ខខណ្ឌទាមទាររបស់សមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនីមួយៗ ដើម្បីបង្ការទប់ស្កាត់ការឆ្លងរាលដាលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវសមាសភាពចង្រៃតាមសកម្មភាពនាំចូលនូវទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ។

**ឆ-វិញ្ញាបនបត្រុបញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ** :(Certificate for New Plant Variety Protection)

សំដៅដល់លិខិតបញ្ជាក់សិទ្ធិអ្នកបង្កាត់ពូជដំណាំ ដែលផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលនូវសិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ និងចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ជ-វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ:** (Certificate for Seed Quality)

សំដៅដល់លិខិតបញ្ជាក់ពីគុណភាពពូជដំណាំ ហើយផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិ-

ROYAUME du CAMBODGE

បុគ្គល ក្រោមកម្មវត្ថុធ្វើអាជីវកម្មពូជដំណាំ និង ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ន-សមាសភាពចង្រៃ:** (Pest)

សំដៅដល់គ្រប់សត្វ និង រុក្ខជាតិ ទោះជាងាប់ ឬ រស់ក៏ដោយឱ្យតែក្នុងដំណាក់កាលលូតលាស់ណាមួយ វាអាចបង្កគ្រោះថ្នាក់ ឬ បំផ្លាញដំណាំ ។ សមាសភាពចង្រៃទាំងនោះរាប់បញ្ចូលសត្វល្អិត ចៃ កណ្តុរ ខ្យង បក្សី សីរៈ ដែលបង្កជំងឺដល់ដំណាំ និងស្មៅចង្រៃ ។

**ប-ស្លាកសុវត្ថិភាព:** (Safety Seal)

សំដៅដល់សំណាបិទភ្ជិត ដើម្បីធានាថា ទំនិញនៅក្នុងខ្ចប់ថែនណីមានសុវត្ថិភាព ឬ ពុំមានការប៉ះពាល់ធ្វើឱ្យខុសភាពដើម ។

**ផ-ស្តង់ដារ:** (Standard)

សំដៅដល់ខ្នាតគំរូមួយ ដែលត្រូវបានកំណត់ដោយច្បាប់នេះ ដើម្បីកំណត់គុណភាពពូជដំណាំ ។

**ព-ភ្នាក់ងារអធិការកិច្ចពូជដំណាំ:** (Seed Inspector)

សំដៅដល់អង្គភាពទទួលបន្ទុកការងារគ្រប់គ្រង និង ត្រួតពិនិត្យគុណភាពពូជដំណាំ ដែលមានរចនាសម្ព័ន្ធច្បាស់លាស់រួមមាននាយកដ្ឋានកម្មក្រសាស្ត្រ និងកែលំអដីកសិកម្ម និងការិយាល័យកម្មក្រសាស្ត្រ និងកែលំអដីកសិកម្មខេត្ត-ក្រុង ។

**ភ-អាជីវកម្មពូជដំណាំ:** (Seed Bussines)

សំដៅដល់ការផលិត ការកែច្នៃ ការបណ្តុះកូនដំណាំ ការនាំចេញ-នាំចូល និងចរាចរណ៍ពូជដំណាំ ។

**ម-អ្នកបង្កាត់ពូជ ឬ រុក្ខជម្រើសទិន្ន:** (Plant Breeder)

សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើការអភិរក្ស អភិវឌ្ឍ ឬ បង្កាត់ ពិសោធសាកល្បង ជ្រើសរើស និង រំដោះពូជដំណាំ និងរុក្ខជាតិ ដើម្បីបុព្វហេតុបសិដ្ឋកម្មពូជដំណាំស្បៀង និង កសិកម្មប្រកបដោយនិរន្តរភាព ។